# ការធានាគុណភាពក្នុងការផ្តល់សេវាកម្មផ្សេងៗពីនាយកដ្ឋានសុខភាពផ្លូវចិត្តនៃខោនធី Los Angeles

## សេចក្តីជូនដំណឹង

ថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2024

សៀវភៅផ្តល់ព័ត៌មានសម្រាប់អ្នកទទួលបានអត្ថប្រយោជន៍របស់នាយកដ្ឋានសុខភាពផ្លូវចិត្តនៃខោនធី Los Angeles (Los Angeles County Department of Mental Health [LACDMH] Beneficiary Handbook) គឺបានធ្វើឱ្យថ្មីឡើងវិញ និងបានផ្លាស់ប្តូរឈ្មោះទៅជា សៀវភៅផ្តល់ព័ត៌មានដល់សមាជិកអំពីសុខភាពផ្នែកអាកប្បកិរិយាប្រចាំខោនធី Los Angeles (Los Angeles County Behavioral Health Member Handbook) គិតចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2025 តទៅ ហើយអាចរកបានជាច្រើនភាសាខុសៗគ្នានៅលើគេហទំព័ររបស់ LACDMH តាមរយៈ៖ https://dmh.lacounty.gov/។ ដើម្បីទទួលបានច្បាប់ចម្លងជាលក្ខណៈបោះពុម្ពដោយមិនគិតថ្លៃ សូមស្នើសុំតាមរយៈអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ហើយអ្នកនឹងទទួលបានមួយច្បាប់ក្នុងអំឡុងពេលប្រាំ (5) ថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ)។

ការធ្វើឱ្យថ្មីឡើងវិញទាំងឡាយនៅក្នុងសៀវភៅផ្តល់ព័ត៌មានដល់សមាជិកនេះរួមមានព័ត៌មានអំពីការដាក់បញ្ចូលសេវាកម្មផ្សេងៗផ្នែកសុខភាពផ្លូវចិត្តបែបជំនាញពិសេស និងផ្នែកបញ្ហាប្រើប្រាស់សារធាតុញៀន ហើយនិងសេវាកម្មផ្សេងៗពីគំនិតផ្តួចផ្តើមដែលអនុញ្ញាតឱ្យអ្នកធ្លាប់ជាប់ឃុំឃាំងអាចចុះឈ្មោះចូលកម្មវិធីធានារ៉ាប់រង Medi-Cal បាន (Justice-Involved Reentry)។

ប្រសិនបើអ្នកត្រូវការជំនួយជាភាសារបស់អ្នក ជំនួយឬសេវាកម្មបន្ទាប់បន្សំសម្រាប់ពិការភាពរបស់អ្នក ឬក៏ដើម្បីទទួលបានឯកសារផ្សេងៗជាអក្សរសម្រាប់មនុស្សមើលមិនឃើញ (braille) ឬជាអក្សរពុម្ពធំៗនោះ ចំណុចទាំងនេះគឺអាចរកបាននៅពេលស្នើសុំ តាមរយៈការទូរស័ព្ទទៅកាន់លេខ 1-800-854-7771 (លេខសម្រាប់អ្នកថ្លង់ [TTY]៖ 711)។ សេវាកម្មទាំងនេះគឺមិនគិតថ្លៃនោះទេ។

(Cambodian)